# មជ្ឈមណ្ឌលឯកសារកម្ពុជា

## សម្ភាសន៍ជាមួយ ផាន់ ផល ភេទស្រី អាយុ៦០ឆ្នាំ

## ស្រុកកំណើតនៅភូមិត្រពាំងទន្លេ ឃុំអណ្តូងខ្ពស់ ស្រុកបុរីជលសា ខេត្តតាកែវ

## សព្វថ្ងៃរស់នៅភូមិអូរស្វាយក្នុង ឃុំអូរស្វាយ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## មុខងារសម័យខ្មែរក្រហមៈ កម្មាភិបាលពេទ្យស្រុកនៅខេត្តកោះកុង

## ថ្ងៃទី៣០ ខែសីហា ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ ឡុង ដានី

## ០០:៥០:៥៣

## ២៨ទំព័រ

ដានីៈ សុំសួរឈ្មោះអ៊ីម្តងទៀត អ៊ីឈ្មោះ?

ផលៈ ផាន់ ផល ។

ដានីៈ ផាន់ ផល ឬផាន់ សុផល?

ផលៈ ផាន់ ផល ។ ដាក់សុផល ក៏ដាក់ទៅ មិនបាច់លុបទេ ។

ដានីៈ ផាន់ ផល ។ អ៊ីអាយុប៉ុន្មាន?

ផលៈ អាយុដាក់៦០ ។

ដានីៈ អ៊ីកើតឆ្នាំ?

ផលៈ ១៩៥៣ ។

ដានីៈ បើឆ្នាំខ្មែរយើងឆ្នាំ?

ផលៈ ឆ្នាំមមី ។

ដានីៈ ស្រុកកំណើតកើតជាអ៊ីនៅភូមិ?

ផលៈ ភូមិត្រពាំងទន្លេ ។

ដានីៈ ឃុំ?

ផលៈ ឃុំអណ្តូងខ្ពស់ ។

ដានីៈ ស្រុក?

ផលៈ ស្រុកបុរីជលសា ។

ដានីៈ ខេត្ត?

ផលៈ ខេត្តតាកែវ ។

ដានី:	អ៊ំមានបងប្អូនប៉ុន្មាននាក់ដែរ? បងប្អូនបង្កើត ។

ផល:	បងប្អូនបង្កើត៧នាក់ ។

ដានី:	ច្រើនដែរ ស្រីប៉ុន្មាន ប្រុសប៉ុន្មានទៅ?

ផល:	ស្រី៦ ប្រុសមួយ ។

ដានី:	ស្រី៦នាក់ ប្រុសតែម្នាក់ទេ?

ផល:	ចា៎!

ដានី:	ហើយអ៊ំកូនទីប៉ុន្មាន?

ផល:	ខ្ញុំកូនបងគេបង្អស់ ។

ដានី:	ឪពុកអ៊ំគាត់ឈ្មោះអីដែរ?

ផល:	ឪពុកខ្ញុំឈ្មោះ ផូ ស្លាប់យូរហើយ ។

ដានី:	ស្លាប់តាំងពីអ៊ំអាយុប៉ុន្មាន?

ផល:	តាំងពីខ្ញុំអាយុ១២ឆ្នាំ ។

ដានី:	ហើយម្តាយ?

ផល:	ម្តាយឈ្មោះ យឹម តែស្លាប់ដែរ ។

ដានី:	គាត់ស្លាប់តាំងពីអង្កាល់?

ផល:	ទើបតែស្លាប់ឥឡូវៗនេះដែរ ២-៣ឆ្នាំ ។

ដានី:	គាត់មកនៅហ្នឹងជាមួយអ៊ំ?

ផល:	អត់ទេ នៅស្រុក ។

ដានី:	អ៊ំបងប្អូនប៉ុន្មាននាក់ដែលមករស់នៅនេះជាមួយអ៊ំ?

ផល:	មកនៅនេះ៥នាក់ ។

ដានី:	អីចឹងរស់នៅ៥ នៅស្រុកប៉ុន្មាននាក់ទៅ?

ផល:	២នាក់ ។

ដានី:	ស្រុកតែ២នាក់ទេ?

ផល:	ចា៎!

ដានី:	អ៊ំកាលពីក្មេងៗរៀនសូត្រដល់ណាដែរ?

ផល:	ខ្ញុំរៀនបានថ្នាក់ទី១០ ។

ដានី:	ថ្នាក់ទី១០ ពីដើម?

ផលៈ ចា៎! តែបានតិច ។

ដានីៈ អ៊ំចេះអាន ចេះសរសេរច្បាស់ទេ ។

ផលៈ សរសេរមិនកើតទេឥឡូវ មើលលែងឃើញ ភ្នែកងងឹតអស់ហើយ ។

ដានីៈ តែពីមុនមក?

ផលៈ ពីមុនអានសរសេរកើត ។

ដានីៈ អ៊ំឈប់រៀនតាំងពីឆ្នាំណាទៅ?

ផលៈ យូរណាស់ យើងមុនរដ្ឋប្រហារឆ្នាំ៧០ទៀត ។

ដានីៈ រដ្ឋប្រហារឆ្នាំ៧០?

ផលៈ មុនហ្នឹងទៀត ហ្នឹងប្រហែលជាខួង៦៨-៦៩ ។

ដានីៈ ដល់ពេលឈប់រៀនហើយធ្វើអីទៅ?

ផលៈ នៅផ្ទះធ្វើស្រែជាមួយម៉ែ ។

ដានីៈ នៅផ្ទះយើងធ្វើស្រែ?

ផលៈ ចា៎!

ដានីៈ ដល់ឆ្នាំណាទៅបានអ៊ំចូលទៅជាមួយគេ ជាមួយឯង?

ផលៈ ទៅជាមួយគេ ជាមួយឯងឆ្នាំ៧២ ។

ដានីៈ ឆ្នាំ៧២?

ផលៈ ចា៎!

ដានីៈ កាលហ្នឹងយើងស្ម័គ្រចិត្តទៅជាមួយគេ ជាមួយឯង ឬក៏មានការចាត់តាំងពីខាងភូមិ ខាងឃុំ?

ផលៈ គេមិនចាត់តាំងទេ តែមើលទៅឃើញការងារគេប្រើមិនឈប់ពេកខ្ជិលចេញឲ្យផុត ។

ដានីៈ ចេញពីផ្ទះទៅ?

ផលៈ ចា៎! ចេញពីផ្ទះ គេមិនចាត់តាំងថាឥឡូវមិត្តឯងត្រូវទៅ គេហៅថាមិត្តកាលហ្នឹង ។

ដានីៈ បាទ!

ផលៈ គេមិនថាទេ តែតិចទៅនេះ តិចទៅនោះ ប្រើពេក ប្រើទាំងម៉ែ ប្រើទាំងកូន ខ្ញុំខ្ជិលនៅឲ្យអ្នកណាប្រើ ។

ដានីៈ ឆ្នាំ៧២?

ផលៈ ចា៎! ចេញឲ្យផុតទៅ ។

ដានី៖ ឆ្នាំ៧២អ៊ំទៅនៅណាទៅ?

ផល៖ នៅកន្លែងមន្ទីរឃុំ ។

ដានី៖ ឃុំ?

ផល៖ កាលហ្នឹងគេហៅឃុំអន្លុង្គរ ។

ដានី៖ អីចឹងឃុំអណ្តូងខ្ពស់ក្រោយទេ?

ផល៖ ក្រោយទេ អណ្តូងខ្ពស់យើងបង្កើតឥឡូវនេះ ។

ដានី៖ កាលមុនអន្លុង្គរទេ?

ផល៖ ចា៎!

ដានី៖ នៅធ្វើអីទៅនៅអន្លុង្គរ?

ផល៖ អត់មានធ្វើស្អី បុគ្គលិកធម្មតា ដាំបាយ កាលហ្នឹងគេហៅកម្មាភិបាល ឈ្លប ហូប គ្មានធ្វើអី ។

ដានី៖ កាលហ្នឹងអ៊ំអាយុប៉ុន្មានឆ្នាំ?

ផល៖ ខ្ញុំមិនទាន់២០ទេ ។

ដានី៖ នៅក្មេងដែរ?

ផល៖ ក្មេង ទើប១៦-១៧ឆ្នាំ ។

ដានី៖ នៅដាំមន្ទីរឃុំ?

ផល៖ ចា៎! ដល់ក្រោយមកបានចេញពីឃុំទៀត មិនបាននៅហ្នឹង ។

ដានី៖ នៅបានរយៈពេលប៉ុន្មានបានចេញ?

ផល៖ ៧៣គេឲ្យទៅនៅភ្នំដិន ដល់ឈើពេក ។

ដានី៖ ឆ្នាំ៧៣ទៅនៅភ្នំដិន?

ផល៖ ចា៎!

ដានី៖ ខាងតាកែវ ខាងព្រំដែន?

ផល៖ ចា៎!

ដានី៖ ធ្វើអីគេទៅភ្នំដិន?

ផល៖ នៅក្រុមនារី ។

ដានី៖ នៅជាមួយពីណា?

ផល៖ នៅជាមួយ ក្មេងឈ្មោះមេហ្នឹងបាត់ហើយ ។

ដានី៖ យូរហើយ?

ផលៈ ចា៎! ភ្លេចហើយ។

ដានី៖ ស្រីៗទាំងអស់ក្រុម?

ផលៈ ចា៎! ស្រី។

ដានី៖ សុទ្ធតែនារី?

ផលៈ កងវរៈហ្នឹងឈ្មោះស្អីភ្លេចហើយ។

ដានី៖ ទៅនៅភ្នំដិនបានរយៈពេលប៉ុន្មានទៅ?

ផលៈ តិចដែរទេ។ ៧៣-៧៤ឡើងមកនេះ ពេជ្រនិល។

ដានី៖ មកពេជ្រនិលវិញ?

ផលៈ ចា៎! ពេជ្រនិលហ្នឹងតិចទេ មិនបាននៅរាប់ខែទេ ក៏គេបញ្ជូនមកកោះកុង ចុង៧៣ ដើម ៧៤ហើយ។

ដានី៖ អីចឹងនៅកន្លែងភ្នំដិនពីឆ្នាំ៧៣នៅកងនារីធ្វើអីទៅ? ធ្វើទ័ព?

ផលៈ ទ័ពតែរកស៊ីខ្លួនឯង។

ដានី៖ អត់មានវៃជាមួយយួនទេ?

ផលៈ អត់ទេ ធ្វើរកតែបន្លែ រកម្ហូបគ្មានស្អីស៊ីទេ នៅនោះលុតដី ស្ងួរចេក ស្ងួរខ្នុរជំនួសបាយ មិនដែលស្គាល់គ្រាប់អង្ករម៉េចទេ និយាយទៅដូចគេយកយើងទៅលុតដី។

ដានី៖ នៅភ្នំដិនហ្នឹង?

ផលៈ ចា៎! លុតដី មិនមែនយកទៅវៃ យកទៅតប់អត់ទេ គ្មានស្អីហូបទេ រកស្អីមកជួនកាលស្ងួរ អត់អំបិលទៀត។ ខ្ញុំទៅដល់ដំបូងអត់ដឹងធ្លាប់នៅភូមិមានបាយហូប ទៅដល់គេថាមកហូប បាយៗ ទៅអើតមានតែសម្លរដួស នាំគ្នាមើលមុខគ្នា ដល់៤-៥ថ្ងៃសាំហើយចេះតែហូប នឹងគេឯង ហើយចាប់ផ្តើមឈឺហើយ។ ឈឺនោះមិនដែលស្គាល់ការងាររអីនឹងគេទេ ញាក់ រហូត។

ដានី៖ ដល់ពេលអីឆ្នាំប៉ុន្មាន ៧៤បានផ្លាស់មកពេជ្រនិល?

ផលៈ ចា៎! មកពេជ្រនិល មកកោះកុង។

ដានី៖ មកពេជ្រនិលមកធ្វើអីទៅ?

ផលៈ ពេជ្រនិលគេបញ្ជូនមកកោះកុង តែយើងមកតាមរយៈហ្នឹង។

ដានី៖ នៅពេជ្រនិលបានរយៈពេលខ្លីទេ? ប៉ុន្មានខែទៅ?

ផលៈ អត់បានរាប់ខែទេ គ្រាន់តែសំរាកបាត់ហត់ បាត់ហេវ បញ្ជូនដល់កោះកុង ។

ដានីៈ ឆ្នាំប៉ុន្មានដល់កោះកុង?

ផលៈ ឆ្នាំ៧៨ ។

ដានីៈ អីចឹងឆ្នាំ៧៨ អត់ទាន់បែកភ្នំពេញទេ?

ផលៈ នៅទេ វៀតណាំងអស់ សុទ្ធតែដើរវៀងកាត់ព្រៃ ។

ដានីៈ ទៅដល់កោះកុងទៅនៅណាទៅ?

ផលៈ ទៅនៅម្តុំព្រែកជីក ម្តុំគេហៅខ្សាច់ស- ក្អែកទឹក នៅម្តុំហ្នឹង ។

ដានីៈ ៧៨ហ្នឹងនៅកោះកុងគេហៅតំបន់?

ផលៈ ១១ ។

ដានីៈ តំបន់១១កាលហ្នឹង?

ផលៈ ចាំ! កាលហ្នឹងហៅ១១ ។

ដានីៈ អ្នកណាគេគាត់ជាគណៈតំបន់?

ផលៈ ពូរ៉ន ។

ដានីៈ រ៉ន?

ផលៈ ស្លាប់បាត់ហើយឥឡូវ ។

ដានីៈ គាត់ធ្វើគណៈតំបន់?

ផលៈ ចាំ!

ដានីៈ តាឈ្មោះ ចុង, ប្រសិទ្ធិ គាត់ធ្វើនៅហ្នឹងដែរ?

ផលៈ បាត់អស់ហើយ ខ្ញុំមកបាត់អស់ហើយ ។

ដានីៈ នៅសល់តែ រ៉ន?

ផលៈ តារ៉ន, តានៅ ។

ដានីៈ តានៅ ណា?

ផលៈ តានៅ ដល់សម័យគេចាប់ខ្លាំងគាត់រត់ចូលវៀតណាមរួចខ្លួនគាត់ ។

ដានីៈ ចុះតារ៉ន គេចាប់គាត់?

ផលៈ គេអត់ចាប់ទេ យ៉ាងម៉េចទេ ផ្លាស់មកខាងកំពង់ស្ពឺ ថាស្អីវិញក្រឡាប់បាក់ដៃ បាក់ជើង ក្រោយមកឈឺស្លាប់ទៅ ។

ដានីៈ អីចឹងពេលអ៊ំទៅដល់កោះកុងនៅក្នុងមន្ទីរអីគេទៅ?

ផលៈ ទៅដល់មុនដំបូងនៅក្រុមនារីហ្នឹង ក្រោយមកកាលហ្នឹងដែលគាត់សួរគណៈ គាទិត ខ្ញុំអត់ស្គាល់ទេ តែបាត់អស់ហើយគ្មានអ្នកនៅហ្នឹងចាស់ កាលហ្នឹងគេស្រាវជ្រាវរើសបុគ្គលិកពេទ្យ ខ្ញុំបានចូលពេទ្យនឹងគេទៅ ។

ដានីៈ ក្នុងពេទ្យហ្នឹងយើងនៅពេទ្យតំបន់ ឬពេទ្យយ៉ាងម៉េច?

ផលៈ ពេទ្យតំបន់ ។

ដានីៈ ពេទ្យតំបន់១១ហ្នឹង?

ផលៈ ចា៎!

ដានីៈ គ្នាច្រើនទេធ្វើពេទ្យ?

ផលៈ គ្នាមិនច្រើនប៉ុន្មានទេ កាលហ្នឹងគិតផ្សែផ្សំតិចតួច រើសពីនេះ ពីនោះ មិនទាន់បាន ១០០នាក់ផង បានតិចដែរទេ ។

ដានីៈ យើងទៅបណ្តុះបណ្តាល ទៅរៀនសូត្រវិជ្ជាពេទ្យពីណាទៅ?

ផលៈ កាលហ្នឹងមេៗមិនដឹងគេរៀនពីណាទេ ខ្ញុំមិនសូវដឹងដែរ ។

ដានីៈ តែកាលហ្នឹងអ៊ំអត់មានទៅរៀនអី ចាក់ថ្នាំ រៀនមើលជំងឺត្រូវថ្នាំអី?

ផលៈ នៅទេ ។

ដានីៈ កាលហ្នឹងពីណាទៅធ្វើអ្នកគ្រប់គ្រងខាងពេទ្យ?

ផលៈ ពូស៊ីង តែគេចាប់គាត់បាត់ហើយ ។ ពូស៊ីង ហ្នឹងនៅតាកែវដែរ ។

ដានីៈ អ៊ីចឹងនៅកោះកុងឆ្នាំ៧៨ នៅរហូតឬយ៉ាងម៉េច?

ផលៈ នៅរហូតទល់យួនចូលមក បានរត់មកនឹងគេឯង ។

ដានីៈ ដល់ពេលឆ្នាំ៧៨ យើងមិនមែននៅទីក្រុង នៅខេត្តគេទេ?

ផលៈ អត់ទេ អត់មាន នៅដងទង់ទេ ។

ដានីៈ នៅក្នុងព្រៃ?

ផលៈ គាត់ដែលទៅទេអណ្តូងទឹក ។

ដានីៈ នៅកន្លែងអណ្តូងទឹក?

ផលៈ ចា៎!

ដានីៈ មន្ទីរតំបន់គេនៅណាទៅ?

ផលៈ មន្ទីរតំបន់ឡើងពីផែតិចទៅ គេធ្វើមន្ទីរតំបន់ ហើយមន្ទីរពេទ្យនៅជិតវត្តបុទុមសាគរ កន្លែងមានដើមប្រេងខ្យល់ឃើញដើមប្រេងខ្យល់ មានដើមគីនីន ហ្នឹងរបស់ពួកខ្ញុំដាំ ។

ដានី៖ ធំៗហ្នឹង?

ផលៈ ចាំ! ហ្នឹងកន្លែងមន្ទីរពេទ្យហើយ ។

ដានី៖ តែមន្ទីរតំបន់?

ផលៈ មន្ទីរតំបន់ដល់ក្រោយមកតំបន់គេរំលាយចូលគ្នា តំបន់គេទៅនៅកំពង់ត្រាវ នៅស្រែអំបិល វិញ គេរំលាយចូលគ្នា កន្លែងហ្នឹងគេឲ្យស្រុកថ្មស ខ្ញុំនៅមន្ទីរពេទ្យស្រុក ។

ដានី៖ ពេលដែលរំដោះឆ្នាំ៧៩?

ផលៈ នៅហ្នឹង ។

ដានី៖ អ៊ំនៅកោះកុងដដែរ?

ផលៈ ចាំ! នៅកោះកុង ។

ដានី៖ កាលហ្នឹងតំបន់១១ គេរំលាយនៅពេលរំដោះ?

ផលៈ រំលាយហើយ ។

ដានី៖ រំលាយពេលណាទៅបើតាមអ៊ំដឹង?

ផលៈ ភ្លេចបាត់ហើយ ៧៩មិនដឹងជារំលាយហើយនៅទេ តែឃើញការទាក់ទងគ្នាហ្នឹងពីកន្លែង វាលរេញជួបជុំគ្នាដែរពេទ្យ តែមិនដឹងថាបញ្ចូល រំលាយគ្នាពីឆ្នាំប៉ុន្មាន ។

ដានី៖ យើងបែកភ្នំពេញថ្ងៃ១៧ មេសា ឆ្នាំ៧៥ ។

ផលៈ ចាំ!

ដានី៖ យើងបែកហើយនៅមានតំបន់១១ទៀត ឬគេឈប់មានតំបន់១១រំលាយចូលគ្នាតំបន់ ៣៧?

ផលៈ ក្រោយមកគេឈប់ហើយ តែមិនឈប់ខែណា ឆ្នាំណា ខ្ញុំអត់ចាំទេ ។

ដានី៖ តែបើតាមអ៊ំចាំ យើងបែកហើយបានយូរ តំបន់៣៧ និងតំបន់១១?

ផលៈ មិនដឹងជា៧៦ ឬ៧៧ ខ្ញុំភ្លេច ។

ដានី៖ អ៊ំថាឈ្មោះ រ៉ែន គាត់នៅហ្នឹង រំដោះហើយឆ្នាំ៧៩ គាត់នៅហ្នឹងទៀតឬអត់ទេ?

ផលៈ គាត់នៅហ្នឹង ។

ដានី៖ ៧៥-៧៦-៧៧គាត់នៅហ្នឹង ។

ផលៈ នៅហ្នឹងគេអត់ទាន់រំលាយទេ?

ដានី៖ មិនដឹងម៉េច ខ្ញុំវង្វេងកន្លែងហ្នឹងមិនដឹងជាឆ្នាំណាៗ តែដឹងតែក្រោយមកគេបញ្ចូលគ្នា ។

ផលៈ ក្រោយមកគេបញ្ចូលជាមួយតំបន់៣៧វិញ? ហើយមន្ទីរតំបន់នៅបឹងព្រាវ នៅស្រែអំបិលវិញ?

ដានីៈ ចា៎! នៅស្រែអំបិល ។

ផលៈ កន្លែងតំបន់១១ ។

ដានីៈ តំបន់១១គេ?

ផលៈ គេឈប់ហើយកន្លែងវត្តហ្នឹងគេធ្វើមន្ទីរស្រុកថ្មស ។

ដានីៈ ពេទ្យតំបន់មកនៅណាវិញទៅ?

ផលៈ ពេទ្យតំបន់នៅបឹងព្រាវហ្នឹងដែរ ។

ដានីៈ អ៊ុំផ្លាស់មកបឹងព្រាវដែរ?

ផលៈ អត់ទេ ខ្ញុំគេឲ្យនៅស្រុក ។

ដានីៈ នៅទទួលពេទ្យស្រុកហ្នឹងទៅ?

ផលៈ ចា៎! មិនទទួលទេ មានគេធំជាងខ្ញុំទៀត ខ្ញុំគ្រាន់ពេទ្យធ្វើថ្នាំ ។

ដានីៈ ថ្នាំគេធ្វើម៉េចទៅកាលហ្នឹងពេទ្យ?

ផលៈ កាលហ្នឹងថ្នាំមិនដឹងគេយកមេម្សៅមកពីណាទេ មានមេម្សៅក្លុយកូរហ្នឹង ហើយយើងបិតទឹកធ្វើសារ៉ូមចាក់ហ្នឹង ធ្វើសារ៉ូមប្រៃ ។

ដានីៈ កាលជំនាន់ហ្នឹងអ្នកជំងឺច្រើនឈឺអីទៅ?

ផលៈ គ្រុនចាញ់ ។

ដានីៈ ជំងឺគ្រុនចាញ់?

ផលៈ ចា៎!

ដានីៈ ថ្នាំដែលអ៊ុំផលិតហ្នឹងមានប្រសិទ្ធភាពអាចព្យាបាលបានទេ?

ផលៈ បានដែលតា៎! ដូចថាអ្នករបួសយើងរុំហ្នឹងឯង មិនដឹងមេម្សៅយកពីណាទេ យកមកយើងរៀនហ្នឹងគេប្រាប់ធ្វើម៉េច ធ្វើអ៊ីចឹង ថ្លឹងហើយដូចថាមួយមីលីលីត្រដាក់ប៉ុន្មាន ៥០មីលីក្រាមដាក់អ៊ីចឹងទៅ ។ ធ្វើបានកាលហ្នឹងធ្វើបានតែវីតាមីនសេ, សារ៉ូមប្រៃ, ផ្អែម៥ភាគរយប៉ុណ្ណឹងទេ ។

ដានីៈ ធ្លាប់បានមកលេងផ្ទះទេ ពេលទៅដល់កោះកុង?

ផលៈ អត់ ។

ដានីៈ អត់ដែលសោះ?

ផលៈ សុំម្ដងគាត់ថាវិចការ៉ាបិតមួយ ចបមួយចាំទៅ ។

ដានីៈ សុំពីណា?

ផលៈ សុំគណៈតំបន់ ដល់អីចឹងអត់ ។

ដានីៈ សុំពីណាគេ?

ផលៈ សុំពូវ៉ន ។

ដានីៈ គណៈតំបន់ពូវ៉ន?

ផលៈ វ៉ន ។

ដានីៈ មានប៉ុន្មាននាក់គណៈតំបន់កាលហ្នឹង?

ផលៈ កាលហ្នឹងខ្ញុំដឹងថាមានពូវ៉ន, តានៅ, តាសៀវ តែតាសៀវ ក៏គេចាប់គាត់បាន ពូនៅ គាត់រត់រួច ។

ដានីៈ គាត់រត់ចូលទៅស្រុកយួន?

ផលៈ ចា៎!

ដានីៈ អ៊ំអត់ដែលមកផ្ទះសោះ?

ផលៈ អត់! និយាយរួមទើបតែបានទៅយើងផ្ដាច់ខ្លួនហើយ សមាហរណកម្ម ។

ដានីៈ កាលហ្នឹងអ្នកជំងឺច្រើនដែលអត់?

ផលៈ ច្រើន ក្រោយពីតំបន់គេប្រគល់ឲ្យស្រុកដាច់មក ៥០០, ៣០០, ៤០០ ច្រើន ។

ដានីៈ មួយថ្ងៃ?

ផលៈ ចា៎! ច្រើន ។

ដានីៈ ភាគច្រើនជំងឺគ្រុនចាញ់?

ផលៈ ចា៎! គ្រុនចាញ់ ។

ដានីៈ គ្រុនចាញ់កាលហ្នឹងភាគច្រើនយើងព្យាបាលជា ឬក៏មិនជា?

ផលៈ ជាដែលហ្នឹង ។

ដានីៈ អត់សូវមានស្លាប់ទេ?

ផលៈ ស្លាប់ដែរ ។ តែកាលហ្នឹងអត់បាយផង អ្នកស្គមស្គាំងខ្លាំងជួយអត់បានដែរ ។

ដានីៈ កាលហ្នឹងអ៊ំមានគ្រួសារនៅ?

ផលៈ នៅទេ ។ ខ្ញុំទើបនឹងយក៨៧នេះទេ នៅក្រមុំចាស់រហូត កាលហ្នឹងខ្ញុំនៅក្មេងដែលទេ ទើប ២០ជាង សម័យនោះគេបន្ទុំដែលតែអត់ ។

ដានី:	អត់យក?

ផលៈ	ប្រកែកទាល់តែរួច ឃើញគេមុខៗការហើយគេចាប់ប្តីទៅ ដល់អីចឹងខាងលើហៅសួរ បើពូហ៊ានទទួលខុសត្រូវខ្ញុំ ខ្ញុំយក ការហើយកុំចាប់ប្តីទៅណាហ្នឹងយក ការហើយចោទថាក្បត់ចេះ ក្បត់ចុះអត់យកទេ ខ្ជិលណាស់ បើម្នាក់ឯងខុសឆ្គង ។

ដានី:	ពីណាអ្នកសួរហ្នឹង?

ផលៈ	គណៈស្រុក ។

ដានី:	គណៈស្រុកពីណាគេ?

ផលៈ	ស្លាប់បាត់ពូហ្នឹង ។

ដានី:	កាលហ្នឹងនៅកោះកុងមានស្រុកអីខ្លះ?

ផលៈ	ស្រុកថ្មស, ស្រុកថ្មបាំង តែពីរហ្នឹង ។

ដានី:	ថ្មស, ថ្មបាំង ហើយគណៈស្រុកដែលមកសួរអ៊ំគាត់ឈ្មោះអីដែលស្លាប់ហ្នឹង?

ផលៈ	ឈ្មោះ យ៉ន តែស្លាប់បាត់ហើយ ដល់ខ្ញុំលើកសំនួរទៅគាត់ថាខ្ជិលកុំឲ្យមានបញ្ហា មិនបាច់ទេ ។

ដានី:	ឈ្មោះយ៉ន ហ្នឹងអ្នកស្នើរ?

ផលៈ	គាត់មិនស្នើរខ្ញុំទេ តែគាត់អ្នកសួរមតិ ថាឥឡូវមានគេស្នើរតើមិត្តយកមិនយក ។

ដានី:	ថ្មស មានប៉ុន្មាននាក់ទៅ?

ផលៈ	គណៈស្រុក?

ដានី:	គណៈស្រុក!

ផលៈ	កាលហ្នឹងមានបងយ៉ន, បងយ៉ុម (ស្រី) ។

ដានី:	ខាងថ្មបាំង?

ផលៈ	ថ្មបាំងអត់ស្គាល់ទេ ។

ដានី:	ប្រធានមន្ទីរពេទ្យគាត់ឈ្មោះស៊ីង?

ផលៈ	ចា៎! គេចាប់គាត់ ។

ដានី:	គេចាប់គាត់ដែរ?

ផលៈ	ចាប់តាំងពី៧៧នោះ ។

ដានី:	ដល់តំបន់១១គេបញ្ចូលគ្នាទៅ តំបន់១១លែងមានទៀតហើយ?

ផលៈ	ចា! អត់មានទេ ។

ដានី៖ ទៅជាតំបន់?

ផល៖ ៣៧ ។

ដានី៖ តំបន់៣៧ទាំងអស់?

ផល៖ ចា៎! តំបន់៣៧ មានស្រុកថ្មបាំង, ថ្មស, ស្រុកស្រែអំបិល, ព្រៃនប់ ។

ដានី៖ ថ្មស, ថ្មបាំង, ស្រែអំបិល, ព្រៃនប់ តែ៤ស្រុកហ្នឹងទេ?

ផល៖ ចា៎!

ដានី៖ ពេលហ្នឹងគណៈតំបន់ពីណាគេទៅ? គណៈតំបន់៣៧?

ផល៖ ភ្លេចឈ្មោះអ៊ំហ្នឹងអស់ហើយ ភ្លេចហើយអ៊ំៗហ្នឹង ។

ដានី៖ គាត់ចាស់ៗហើយ?

ផល៖ ចា៎! ចាស់ៗ ភ្លេចហើយ ។

ដានី៖ អ៊ំខស្សព្វាហ៍មក ដូចថាយើងនៅកោះកុងខស្សព្វាហ៍មកខាងបឹងព្រាវ ស្រែអំបិលដែរ?

ផល៖ ខ្ញុំមកតែបើកថ្នាំ ពេលតំបន់គេបើកហ្នឹងទៅបើកថ្នាំ ។

ដានី៖ កាលហ្នឹងនៅខាងកោះកុងកងទ័ពច្រើនដែលអត់?

ផល៖ ដូចថាច្រើនមិនច្រើន តែកងទ័ពជំនាន់នោះដល់ជ័យជំនះហើយទៅ យកគ្នាទៅលើកទំនប់ឯវាលរេញអស់វិញ ។

ដានី៖ ទំនប់វាលរេញ?

ផល៖ ចា៎!

ដានី៖ គេហៅទំនប់អីគេនៅវាលរេញ?

ផល៖ មិនដឹង ។

ដានី៖ អ៊ំស្គាល់តាផល ទេ?

ផល៖ តាផល គណៈតំបន់?

ដានី៖ បាទ!

ផល៖ ស្គាល់! ដល់ពេលចូល តាផល ហ្នឹងឯង, តាផល, តាសុំ ។ មិនដឹងម៉េចទេពូកុំសរសេរខ្ញុំភ្លេចហើយ ។

ដានី៖ តាផល ខ្ញុំជួបគាត់ គាត់នៅវាលវែង ។ ឥឡូវគាត់នៅវាលវែង ។

ផល៖ ហ្នឹងហើយ ពូផល ។

ដានី៖ គាត់ស្លឹកត្រចៀកនេះធំៗ ។

ផលៈ ចា៎!

ដានីៈ គាស៊ុំ ខ្ញុំអត់ដែលជួបគាត់ទេ ។

ផលៈ ខ្ញុំមិនដែលឃើញមុខផង លឺតែឈ្មោះទេ មិនដែលឃើញទេ ។

ដានីៈ អីចឹងអ៊ំអត់ដែលមកបណ្តុះបណ្តាលរៀនសូត្រនៅភ្នំពេញ ឬខាងមជ្ឈិមអីអត់ទេ?

ផលៈ ដែលម្តង ទៅរៀន ។

ដានីៈ រៀននៅណា?

ផលៈ រៀននៅភ្នំពេញ រៀនពេទ្យ រៀនហើយមិនទាន់នេះផង សភាពការណ៍ ។

ដានីៈ ដល់ឆ្នាំ៧៩ហ្នឹង?

ផលៈ ហ្នឹងហើយ ។

ដានីៈ ឆ្នាំ៧៩យ៉ាងម៉េច អ៊ំអាចរៀបរាប់ពេលដែលឆ្នាំ៧៩?

ផលៈ ៧៩ដឹងរត់ហើយ ។

ដានីៈ រត់ម៉េចខ្លះទៅ?

ផលៈ រត់ ។

ដានីៈ កាលហ្នឹងឆ្នាំ៧៩ហេតុអីយើងអត់ត្រឡប់ទៅស្រុកកំណើត?

ផលៈ លំបាកណាស់ នយោបាយយើងមើលអត់ឃើញ លឺតែគេថាសម្លាប់ៗចេះតែមក ចេះតែរត់ហើយខ្លាចស្លាប់ លឺថាយួនសម្លាប់អស់ហើយ អីចឹងគិតតែពីពើតហើយអត់មានគិតរឿងផ្ទះ ទៅដល់ព្រំដែនអត់មែនទែន កាលហ្នឹងមិនដឹងពីណាអ្នកបំផុសបំផុលទេ គេថាឥឡូវគេឲ្យទៅផ្ទះវិញ អ្នកណាស្ម័គ្រចិត្ត ខ្ញុំចុះឈ្មោះទៅផ្ទះ ដល់មេគេឃើញគេមិនឲ្យខ្ញុំទៅវិញ ខានទៅ ។

ដានីៈ អ៊ំធ្លាប់ចុះឈ្មោះមកផ្ទះវិញដែរ?

ផលៈ ចា៎! ចុះឈ្មោះមកផ្ទះ ។

ដានីៈ ពេលហ្នឹងអ៊ំនៅណា?

ផលៈ នៅកំរៀង អូរដា ។ ចុះអស់ហើយថាទៅ ទោះបីម៉ែឪស្លាប់អស់សុំគេនៅជាមួយ ។

ដានីៈ ឆ្នាំណា?

ផលៈ ៧៩ជិតចូល៨០ ។

ដានីៈ ចុះជាមួយពីណាគេ?

ផលៈ មិនដឹងពីណាទេ គេចេះតែប្រមូលគ្នាៗ ដល់យកអាហ្នឹងទៅបន្ទាញមេៗ គេស្តីឲ្យទៅ អត់បានទៅ ។

ដានីៈ មេណា?

ផលៈ មេដែលខ្ញុំនិយាយ ពួយ៉ែន ហ្នឹង ។

ដានីៈ ហ្នឹង?

ផលៈ តែគាត់ស្លាប់បាត់ហើយឥឡូវ ។

ដានីៈ គាត់ស្លាប់តាំងពីអង្កាល់?

ផលៈ មិនដឹងតាំងពីអង្កាល់ទេ ខ្ញុំមកនេះគាត់នៅនោះ ។

ដានីៈ តែអ៊ំកាលនៅកោះកុងអត់ទាន់ស្គាល់អ៊ំប្រុសទេ?

ផលៈ អត់ទេ ។

ដានីៈ អត់ដែលលឺ អត់ដែលស្គាល់គ្នាទេ?

ផលៈ អត់ ។

ដានីៈ ដំបូងឆ្នាំ៧៩មកនៅកំរៀង?

ផលៈ ចា៎!

ដានីៈ អ៊ំយ៉ាងម៉េចទៅ ៧៩ យើងមកនៅកំរៀង អូរដា យើងរត់ពីកោះកុង?

ផលៈ ចា៎! រត់ ។

ដានីៈ រត់យ៉ាងម៉េចទៅ?

ផលៈ រត់ ដើរ ។

ដានីៈ តាមកោះកុងសុទ្ធតែព្រៃ?

ផលៈ សុទ្ធតែព្រៃ ដើរទៀកជង ដើរឡើងភ្នំ ថ្មបាំង អីចឹងរហូតដល់ចំណារ ចំណាប់ មកឆ្លងស្ទឹងមេទឹកយើង ចុះម៉ូតូដីថៃ ថៃដឹកមកកំរៀងនេះទៀត ។

ដានីៈ កន្លែងច្រក៤០០?

ផលៈ ចា៎! មកដល់ហ្នឹងមុនដំបូងស្មានគេយកមកវៃចោលយំអើយយំ ។

ដានីៈ កាលហ្នឹងអ៊ំភ័យដែរ?

ផលៈ ភ័យ ។

ដានីៈ យើងមានបទពិសោធន៍យ៉ាងម៉េច បានឃើញគេដឹកស្មានគេយកមកវៃចោល?

ផលៈ	មិនមានពិសោធន៍ម៉េចទេ ឃើញសុទ្ធតែថៃអ្នកដឹក អត់មានឃើញខ្មែរយើងផង ដល់អីចឹង មិនដឹងគេយកទៅណា ។

ដានីៈ	អត់ចេះនិយាយគ្នា?

ផលៈ	អត់ ហើយសុទ្ធតែតាៗស៊ីម្ហូរ ស្ពាយកាំភ្លើង ។

ដានីៈ	តាៗស៊ីម្ហូរ?

ផលៈ	ចា៎! ខ្វះស៊ីម្ហូរ ដូចពួកភូមិគេម៉េចទេ ខ្ញុំក៏មិនយល់ដែរចាស់ៗ ទៅដូវនេះៗ អាខ្វះភ័យពេក ឆ្លើយប្រាប់ថា (បាត់ចៅកូនកំពុងដើររក) ។

ដានីៈ	កាលពីយើងឆ្នាំ៧៩ហ្នឹង អ៊ីរត់មកកោះកុងគឺដើររហូត?

ផលៈ	ចា៎!

ដានីៈ	អ៊ីថាថៃដឹកឡានមក អ៊ីថាមានតាៗកាន់កាំភ្លើង តាៗស៊ីម្ហូរ ខ្មែរយើង ឬថៃ?

ផលៈ	ថៃ ដូចថាខាងយើងទាក់ទងឡានគេដឹកមក ឡានថៃដឹកមក មិនដឹងគេឈ្នួលឬយ៉ាងម៉េច ខ្ញុំមិនដឹងដែរ តែដឹកមក ដឹកពីម៉ៃរូត គេហៅម៉ៃរូត មកចុះនៅកំរៀង ។

ដានីៈ	ចុះនៅកំរៀងហ្នឹង អ៊ីនៅកំរៀងបានរយៈពេលប៉ុន្មានដែរ?

ផលៈ	អត់បានយូរទេ នៅកំពុងតែខ្លាច មិនទាន់នេះផង យួនដេញទៀត រត់អាប៉ាត់អាប៉ាយទៀត

ដានីៈ	ទៅណាទៀត?

ផលៈ	រត់តាមព្រំដែនហ្នឹង រត់គេចចុះ គេចឡើង ។

ដានីៈ	តែនៅម្តុំសំឡូតហ្នឹង?

ផលៈ	ចា៎! នៅម្តុំហ្នឹង ។

ដានីៈ	រួចម៉េចទៀតទៅអ៊ី?

ផលៈ	ដល់ហើយសសៀរៗមកនៅកន្ទែងបងយុត ដែលថាទៅជួបហ្នុង ។

ដានីៈ	ជួបជាមួយអ៊ីយុត?

ផលៈ	ចា៎!

ដានីៈ	មកជួបគាត់នៅណា?

ផលៈ	នៅមកនៅគេហៅថាគីឡូ១២ ។

ដានីៈ	គីឡូ១២ ខាងភ្នំព្រឹក ។

ផលៈ	តែខ្ញុំនៅខាង៣២ ។

ដានីៈ	ដល់ជួបគាត់ម៉េចទៀតទៅ?

ផលៈ មានអីនៅតាមកន្លែងអង្គភាពមួយៗ ម្នាក់ៗ អត់មានអីទេ ។

ដានីៈ កាលហ្នឹងអ៊ំយុត គាត់ធ្វើគណៈគ្រប់គ្រងនារី?

ផលៈ គាត់គ្រប់គ្រងប្រជាជន តែខ្ញុំនៅកន្លែងពេទ្យតាមព្រំដែន ។

ដានីៈ អ៊ំយុតគាត់គ្រប់ប្រជាជននៅ...?

ផលៈ ប្រជាជនដែលរត់មកជាមួយហ្នឹង ។

ដានីៈ កាលហ្នឹងច្រើនទេ?

ផលៈ ច្រើនដែលហ្នឹង ។

ដានីៈ អ៊ំនៅខាងពេទ្យដដែល?

ផលៈ ចាំ!

ដានីៈ នៅហ្នឹងបានយូរទេ?

ផលៈ នៅយូរដែរ ពី៧៩ដល់៨៣ បានអ៊ំខៀវ (សុន សេន) គេសម្លាប់ហ្នឹង គាត់យកខ្ញុំមក ១០០១ វិញ ។

ដានីៈ ម៉េចបានគេយកអ៊ំមក?

ផលៈ ខាងនេះអត់មានសូវមានមនុស្ស អត់សូវមាននារី អីចឹងយកនារីពីនោះមក៣៣នាក់យកមករៀបចំមន្ទីរ ទុកដាក់ឥវ៉ាន់ សម្ភារៈ ។

ដានីៈ ឆ្នាំ៨៣អ៊ំចេញពីខាងកំរៀង ចេញពីភ្នំព្រឹក?

ផលៈ ខាងនោះមកនៅនេះ ។

ដានីៈ អ៊ំសុន សេន គាត់យកនារី៣៣នាក់?

ផលៈ ចាំ!

ដានីៈ ដោយសារនៅខាង១០០១?

ផលៈ អត់សូវមាននារី ។

ដានីៈ យកទៅធ្វើអីហ្នឹង?

ផលៈ យកមកទុកដាក់សម្ភារៈ ។

ដានីៈ សម្ភាៈឃ្លាំងគាត់?

ផលៈ ចាំ! ឃ្លាំងគាត់ អង្ករអីចឹងហ្នឹង ។

ដានីៈ កាលហ្នឹងអ៊ំស្គាល់អ៊ំហឿន ទេ?

ផលៈ អ៊ំហឿន?

ដានី៖ ហឿន គាត់អ្នកនៅត្រាំកក់ ។

ផល៖ អត់ស្គាល់ទេ ។

ដានី៖ គាត់ឈ្មោះ អ៊ុល ហឿន ។

ផល៖ ខ្ញុំអត់ស្គាល់ទេ ។

ដានី៖ គាត់ត្រូវជាប្អូនថ្លៃតាដឹម ដែរ?

ផល៖ អត់ទេ ខ្ញុំអត់ស្គាល់ ។

ដានី៖ មើលចេញពីហ្នឹងទៅនៅ១០០១ នៅទន្លេល្អៅហ្នឹង ទៅនៅហ្នឹងបានប៉ុន្មានឆ្នាំទៅ?

ផល៖ នៅហ្នឹង៨៣-៨៤-៨៥យួនវាយដាច់ទន្លេល្អៅបានរត់ចេញមកព្រំដែនថៃវិញ ។

ដានី៖ ឆ្នាំ៨៣អ៊ំទៅទន្លេល្អៅអ៊ំបានជួបអ៊ំប្រុសនៅ អ៊ំស៊ី?

ផល៖ នៅទេ ។

ដានី៖ បានស្គាល់គ្នានៅ?

ផល៖ អត់ទាន់ស្គាល់ទេ ទាល់តែ៨៤-៨៥បានស្គាល់ ។

ដានី៖ ៨៥បានស្គាល់គាត់?

ផល៖ ដល់យួនវាយទៅមានរបួស ខ្ញុំជូនកំលាំងខ្ញុំទៅកន្លែងពេទ្យគាត់ បានឃើញតាស៊ី ខ្ញុំក៏មិនដែល ដើរទៅកន្លែងគាត់ គាត់ក៏មិនដែលដើរមកកន្លែងខ្ញុំ នៅរៀងខ្លួន ។

ដានី៖ កាលហ្នឹងអ៊ំស៊ី គាត់?

ផល៖ គាត់នៅលីវតែឯង ។

ដានី៖ នៅតែឯង?

ផល៖ គាត់នៅពេទ្យ ។

ដានី៖ គាត់ប្រធានពេទ្យនៅហ្នឹង?

ផល៖ ចាស៎!

ដានី៖ ប្រធានពេទ្យនៅកន្លែង១០០១ហ្នឹង?

ផល៖ ចាស៎!

ដានី៖ គេហៅពេទ្យអីគេហ្នឹង?

ផល៖ គេហៅពេទ្យ១០០១ មិនដឹងពេទ្យអីគេ ។

ដានី៖ មិនមែនពេទ្យក-៧ទេ?

ផល៖ មិនមែនទេ ដល់ពេលយួនវាយ១០០១បែក ទើបមកនៅក-៧ គាត់ឈប់ពេទ្យវិញហើយ ។

ដានី៖ កាលហ្នឹងគាត់ធ្វើពេទ្យ គាត់ប្រធានពេទ្យ គាត់នៅជាមួយពីណាខ្លះ?

ផលៈ គាត់នៅជាមួយពូលន, ពូអុត ហ្នឹងខាងបច្ចេកទេស ។

ដានី៖ កាលហ្នឹងគាត់នៅតែឯងអត់មានប្រពន្ធ កូនទេ?

ផលៈ ចាំ! អត់ទេ ។

ដានី៖ អ៊ំដឹងថាគាត់មានប្រពន្ធ កូនទេពីមុនមក?

ផលៈ ដឹងតាំ ។

ដានី៖ គាត់ប្រាប់ ឬអ៊ំដឹងថាម៉េច?

ផលៈ គាត់ប្រាប់ តែដឹងថាបាត់ប្រពន្ធគាត់ ។

ដានី៖ ប្រពន្ធគាត់ឈ្មោះអីទៅ?

ផលៈ ឈ្មោះអីទេ ដៃ ។

ដានី៖ «ដ» ដាក់ «ៃ»?

ផលៈ ចាំ!

ដានី៖ កូនគាត់មានប៉ុន្មាននាក់?

ផលៈ កូនគាត់៥ ។

ដានី៖ ពេលហ្នឹងគាត់និយាយប្រាប់អ៊ំហ្នឹងគាត់ការជាមួយអ៊ំហើយ ឬមិនទាន់ទេ?

ផលៈ អត់ទាន់ការទេ និយាយច្បាស់ដឹងរឿងថាប្រពន្ធគាត់បែក តែខ្ញុំ គាត់ស្នើរទៅអ៊ំខៀវ ដល់អ៊ំ ខៀវ គាត់សួរខ្ញុំ ខ្ញុំនឹកឃើញថាខ្ញុំចាស់ហើយ ខ្ញុំមិនអាចដើរជ្រើសរើសខ្លួនឯងទេ យើងស្រី អីចឹងសំរេចតាមដឹកនាំ ទុកដាក់ឲ្យយកប្តីក៏តាមដឹកនាំទៅចុះ ។

ដានី៖ ឆ្នាំណាដែលអ៊ំការជាមួយគាត់?

ផលៈ ៨៦ ។

ដានី៖ តែអ៊ំស្គាល់គាត់តាំងពីមុនហ្នឹង?

ផលៈ ស្គាល់៨៥ហ្នឹងទៅឃើញម្តង ។

ដានី៖ អ៊ំហើយគាត់ឆ្នាំ៨៥ បានស្គាល់គ្នា ទំនាក់ទំនងយ៉ាងម៉េច ឆ្នាំ៨៥មុនដែលគាត់រៀបការ?

ផលៈ អត់មានទំនាក់ទំនងអីផង គាត់សួរថាស្រុកណា គាត់សួរខ្ញុំធ្លាប់នៅណា ខ្ញុំក៏ឆ្លើយតាមហ្នឹង ធ្លាប់នៅណា តែប៉ុណ្ណឹងហើយក៏ហើយទៅ មិនដឹងយ៉ាងណាទេ ។

ដានី៖ ពេលណាគាត់និយាយប្រាប់ថាគាត់ធ្លាប់មានប្រពន្ធ ប្រពន្ធគាត់ឈ្មោះដៃ ហើយកូនគាត់៥ នាក់ គាត់និយាយពេលអ៊ំដឹណាលរឿងប្រាប់ហ្នឹង ឬក៏គាត់ចាប់ផ្តើម?

ផលៈ ពេលគាត់មកសួរសុខទុក្ខ គាត់ថាបាត់គ្រួសារគាត់ បាត់កូនៗ

ដានីៈ កូនគាត់មាន៥នាក់?

ផលៈ ហ្នឹងហើយ រកអត់ឃើញៗ

ដានីៈ គាត់មាននិយាយប្រាប់ថាឈ្មោះអីៗខ្លះ កូនគាត់?

ផលៈ ចាំមិនអស់ទេៗ

ដានីៈ មានចាំប៉ុន្មាននាក់?

ផលៈ ចាំតែមួយឈ្មោះស៊ុយៗ

ដានីៈ ហើយផ្សេងទៀតមានចាំទេ?

ផលៈ ឈ្មោះ អាស្រេង, ហឺមីឡាន់ៗ

ដានីៈ គាត់និយាយប្រាប់អីចឹង?

ផលៈ ចា៎!

ដានីៈ គាត់មាននិយាយថាប្រពន្ធគាត់ ប្រពន្ធពីណាខ្លះដែលបាត់ហ្នឹង?

ផលៈ បាត់ប្រពន្ធគាត់, ប្រពន្ធអ៊ំអាន ម៉ែក្មេកអ៊ំអាន បាត់២គ្រួសារហ្នឹងៗ

ដានីៈ ប្រពន្ធអ៊ំអាន គាត់មាននិយាយប្រាប់ថាឈ្មោះអីដែរ?

ផលៈ អត់ដឹងៗ

ដានីៈ គាត់ប្រាប់ថា គាត់បាត់ប្រពន្ធជាមួយប្រពន្ធអ៊ំអាន?

ផលៈ ចា៎!

ដានីៈ ហើយអ៊ំស្គាល់ អ៊ំអាន ច្បាស់ដែរ?

ផលៈ អ៊ំអាន ស្គាល់នឹងខ្ញុំបានតានេះហើយទេ ពីមុនខ្ញុំអត់ស្គាល់ដូចគ្នា ដល់ពេលបានតានេះគាត់នៅក-៧ហ្នឹង គាត់ធ្លាប់ធ្វើការជាមួយគ្នា ស្គាល់គាត់ទៅមកផ្ទះខ្ញុំ តានេះក៏ទៅផ្ទះគាត់ ស្គាល់ត្រឹមហ្នឹងទេ ពីមុនអត់ទេៗ

ដានីៈ អ៊ំអាន ហើយនិងអ៊ំប្រុសគាត់ធ្វើការជាមួយគ្នា?

ផលៈ ចា៎!

ដានីៈ គាត់ធ្វើការជាមួយគ្នាកាលនៅ?

ផលៈ ក-៧ៗ

ដានីៈ ពីមុនមកហ្នឹងគាត់មានដែលនិយាយប្រាប់ទេ?

ផលៈ អត់ទេៗ

ដានី៖ គាត់ដែលនិយាយថាគាត់នៅកំពង់ចាមទេ?

ផលៈ គាត់ថា គាត់មកពីកំពង់ចាមវិញ តែមិនដឹងថាគាត់ធ្វើអីៗខ្ញុំអត់ដឹង ។

ដានី៖ ពីណាថា អ៊ំប្រុស?

ផលៈ ចាំ!

ដានី៖ អ៊ំប្រុសថាគាត់ធ្លាប់នៅកំពង់ចាមជាមួយអ៊ំអាន?

ផលៈ គាត់និយាយប្រាប់ខ្ញុំប៉ុណ្ណេះ គាត់នៅហ្នឹងគាត់មិនហ៊ានធ្វើអីឲ្យលើសពីប្រជាជនទេ ប្រជាជនហូបអីគាត់ហូបហ្នឹង ដល់ពេលអ៊ំអាន ហើយអ៊ំដឹម មកឃើញអីចឹង គាត់ថា មិត្តស៊ី ធ្វើអីចឹងស្លាប់ហើយ ឲ្យរកអីហូបឲ្យសមរម្យនឹងគេទៅ ហូបអីចឹងធ្វើការស្អារ គេធ្វើអីគាត់ធ្វើហ្នឹង គេលើកទំនប់លើកនឹងគេ ។

ដានី៖ គាត់និយាយអីចឹង?

ផលៈ គាត់ថាកុំតែបានបងអាន និងបងដឹម កុំអី ។

ដានី៖ គាត់និយាយប្រាប់អ៊ំ?

ផលៈ ចាំ! គាត់និយាយអីចឹង គាត់មិនធ្វើអីឲ្យខុសពីប្រជាជនទេមិត្ត គេហៅខ្ញុំមិត្ត ។

ដានី៖ ហៅពីណាគេ?

ផលៈ ហៅខ្ញុំ ។

ដានី៖ កាលហ្នឹងគាត់រៀបការជាមួយអ៊ំនៅ?

ផលៈ រៀបហើយ បានគាត់និយាយអីចឹង ។

ដានី៖ អ៊ំអាន គាត់រាក់ទាក់អត់?

ផលៈ អត់អីទេ គាត់ហៅតែក្មួយ ។

ដានី៖ ហៅក្មួយៗ?

ផលៈ ចាំ!

ដានី៖ ប្រពន្ធក្រោយគាត់ គាត់ការឆ្នាំណាដែរ អ៊ំអាន?

ផលៈ ទើបការឥឡូវៗ ។

ដានី៖ ការមុនអ៊ំ ឬការក្រោយអ៊ំ?

ផលៈ ការក្រោយខ្ញុំ ។

ដានី៖ ប្រពន្ធគាត់ឈ្មោះអីគេ?

ផលៈ ឈ្មោះ រ៉ាន់ ។

ដានី៖ អ៊ីចឹងគាត់ការក្រោយអ៊ំទៀត?

ផល៖ ចា៎! ការក្រោយ ២នាក់ហ្នឹងគាត់បែកប្រពន្ធទាំងអស់ គាត់មិនយកទេ គាត់ចេះតែនៅ រង់ចាំ ក្រែងលោឃើញ។

ដានី៖ អ៊ំប្រុសគាត់ឈ្មោះ?

ផល៖ ស៊ី។

ដានី៖ អីគេ «ស៊ី»?

ផល៖ ប៊ុន ស៊ី។

ដានី៖ គាត់អាយុប៉ុន្មានហើយ?

ផល៖ គាត់៧៣ហើយ។

ដានី៖ គាត់ស្រុកកំណើតគាត់នៅភូមិ?

ផល៖ ភូមិអណ្ដូងថ្ម ឃុំគុស ស្រុកត្រាំកក់។

ដានី៖ ស្រុកត្រាំកក់ ខេត្តតាកែវ។

ផល៖ ចា៎!

ដានី៖ អ៊ំធ្លាប់ទៅលេងស្រុកកំណើតជាមួយគាត់ដែរ?

ផល៖ ចា៎! ទៅ។

ដានី៖ ឆ្នាំ៨៥យួនវ៉ៃបែកនៅទន្លេល្អៅ ហើយម៉េចទៀតទៅ?

ផល៖ បែកទៅគេចេញមកនៅព្រំដែនថៃបានស្គាល់តាហ្នឹង។

ដានី៖ អ៊ំការឆ្នាំ៨៦ ការនៅណា?

ផល៖ ការនៅព្រំដែនថៃ។

ដានី៖ ព្រំដែនថៃនៅកន្លែងណា? គេហៅអីគេ?

ផល៖ នួន សួង។

ដានី៖ នួន សួង កន្លែងហ្នឹង តាខៀវ គ្រប់គ្រងដែលឬអត់ទេ?

ផល៖ ចា៎!

ដានី៖ ដល់ពេលអ៊ំការហើយបានអ៊ំអាន ការប្រពន្ធតាមក្រោយ?

ផល៖ ចា៎! អ៊ំអាន ការនៅគ-៧។

ដានី៖ កាលហ្នឹងអ៊ំបែកពី អ៊ំយុត ហើយ?

ផល៖ បែកហើយ។

ដានី៖ បែកគាំងពី៨៣ ហ្នឹង?

ផល៖ ចា៎!

ដានី៖ អត់ដែលជួបគាត់ទៀតទេ?

ផល៖ អត់ដែលជួប អ៊ុំយុត នៅនោះ ខ្ញុំក៏មកនេះ ។

ដានី៖ អ៊ំប្រុសគាត់ខស្សរាហ៍និយាយថាគាត់ធ្វើការងារ អត់ហ៊ានឲ្យប្រជាជន ខស្សរាហ៍និយាយប្រាប់អ៊ំច្រើនដងទេ?

ផល៖ គាត់និយាយប្រាប់ខ្ញុំ គាត់ថាខ្ញុំមិនដែលធ្វើអីឲ្យខុសពីប្រជាជនទេ ប្រជាជនហូបបបរខ្ញុំហូបបបរ ប្រជាជនរែកដីខ្ញុំរែកដី គាត់ថាអីចឹង គាត់និយាយប្រាប់ខ្ញុំអីចឹង ។ បើនិយាយទៅខ្ញុំប្រាប់ក្មួយឲ្យត្រង់ ខ្លួនគាត់ត្រឹមត្រូវត្រង់ហ្នឹងហើយ គ្មានស្អីនឹងគេទេ ឃើញផ្ទះអីចឹងតិចថាប្រពន្ធមានមាសមួយលី មួយហ៊ុននឹងគេអត់ទេ ។

ដានី៖ គាត់អត់មានមាសសល់ពីនោះ?

ផល៖ អត់ទេ អានេះប្អូនថ្លៃខ្ញុំទេទិញឲ្យប្រាំហ៊ុន ។

ដានី៖ គាត់កាលហ្នឹងនៅកំពង់ចាម លឺដំណឹងថាគាត់ធ្វើអីដែរ?

ផល៖ ខ្ញុំអត់ដឹងដែរ ខ្ញុំអត់បានសួរ ខ្ញុំអត់សួរទេ មិនដឹងគាត់ធ្វើអី ។

ដានី៖ អត់ដឹងថាគាត់ធ្វើគណៈតំបន់ ឬគណៈស្រុកអី?

ផល៖ មិនទេគណៈតំបន់ អត់បានដល់គណៈតំបន់ទេ ។

ដានី៖ មិនបានទេ?

ផល៖ មិនបានទេ ។

ដានី៖ ព្រោះអ៊ំអាន គណៈតំបន់?

ផល៖ ហ្នឹងហើយ ។

ដានី៖ គាត់តូចជាងអ៊ំអាន?

ផល៖ តូចទេ ។

ដានី៖ តែគាត់នៅជាមួយ?

ផល៖ ចា៎! នៅជាមួយ ព្រោះយកពីនោះមក មកនៅអីចឹង ។

ដានី៖ គាត់មកជាមួយគ្នា?

ផល៖ ចា៎! ហ្នឹងហើយ ។

ដានី៖ កាលគាត់នៅស្រុកកំណើតគាត់ធ្វើអី?

ផលៈ	នៅឃុំ ។

ដានីៈ	មានដែលលឺគាត់និយាយរឿងព្រះអង្គម្ចាស់ ដារ៉ាដេប៉ូទេ?

ផលៈ	អត់ទេ អត់ដែលលឺ ។

ដានីៈ	ព្រោះខ្ញុំធ្លាប់លឺមីងសេម គាត់និយាយរឿងព្រះអង្គម្ចាស់ដារ៉ាដេប៉ូ ។ គាត់មាននិយាយថា កាលហ្នឹងព្រះអង្គម្ចាស់ ដារ៉ាដេប៉ូ នៅក្នុងកន្លែងគាត់ដែលអត់ទេ?

ផលៈ	អត់ អត់ដែលនិយាយ ។

ដានីៈ	អុំរៀបការឆ្នាំ៨៦ហ្នឹង យ៉ាងម៉េចទៀតទៅយើងចេញពីណាទៅណា?

ផលៈ	នៅតាមភ្នំដងរែក គេចចុះគេចឡើង ទៅលើថៃឡដី ខាងនេះដីយើង ខាងនោះភ្នំអីចឹងទៅ យើងខាងនេះចេះតែដេញ នៅតាមសរសៀលៗដីថៃ ។

ដានីៈ	នៅជាយដីថៃ?

ផលៈ	ជាយៗ ។

ដានីៈ	ដល់ឆ្នាំណាបានអុំមកនៅនេះ?

ផលៈ	៩០ខ្ញុំចុះមកនៅជិតស្រះឈូក ។

ដានីៈ	ជិតស្រះឈូកនៅខាងអន្លង់វែង?

ផលៈ	គេហៅកន្លែង៨០០ ត្រពាំងប្រិយ៍ ។

ដានីៈ	តម៉េចទៀតទៅ?

ផលៈ	ចុះមកនៅហ្នឹង ក៏តាហ្នឹងមកនៅមុនគេ នាំគេមកនៅហ្នឹង ទឹកល្អក់អីចឹង គេខឹង គេគួរូប បាញ់ ។

ដានីៈ	ឆ្នាំណាដែលមកហ្នឹង?

ផលៈ	៩០ ។

ដានីៈ	ឆ្នាំ៩០ក្រែងចុះមកនៅត្រពាំងប្រិយ៍?

ផលៈ	ចា៎! ត្រពាំងប្រិយ៍គ្មានទឹកទេ ឲ្យម៉ែខូ តាម៉ុក ឲ្យម៉ែខូមកកាយហ្នឹង ទឹកដូចខ្ទួរអណ្តែង គ្មានទឹកប្រើទេអត់ ។

ដានីៈ	នៅត្រពាំងប្រិយ៍បានយូរទេ?

ផលៈ	ត្រពាំងប្រិយ៍បានយូរដែរ ៩០ ។ ៩៥រើអន្លង់វែង ៩៦បានមកនៅទំនប់ដាច់ ដេញមកទៀតបានមកជាប់ហ្នឹង ។

ដានីៈ	ឆ្នាំណាបានមកដល់នេះ?

ផលៈ ៩៦-៩៧, ៩៧មានរឿងរ៉ាវគ្នា ។

ដានីៈ រឿងតាសុន សេន គេសម្លាប់?

ផលៈ ចា៎!

ដានីៈ អ៊ំដឹងដែលរឿងគេសម្លាប់តាសុន សេន?

ផលៈ ទាល់ឃើញស្លាប់ហើយបានដឹង ។

ដានីៈ អ៊ំយល់ឃើញយ៉ាងម៉េចគេសម្លាប់គ្នាចឹង?

ផលៈ ដឹងយល់ឃើញយ៉ាងម៉េចទេ ខ្ញុំចិត្តខ្ញុំវិញខ្ញុំថា ចេះបើសិនជាយើងចង់នេះចឹង ត្រូវរួវជាមួយរដ្ឋាភិបាល កុំឲ្យប្រជាជនវាលំបាកវាហើយ ចាំបាច់សម្លាប់គ្នាធ្វើអី អាហ្នឹងចិត្តមើលឃើញចឹងវិញ នឹកឃើញថាប្រជាជនវាហត់វានឿយវាហេវវារត់យ៉ាប់មាំណាស់ វាលំបាកណាស់ គ្មានទេ ពេលខ្លះចឹងទៅរត់ទៅភៀងមករត់កន្លែងដេកកន្លែងពួន កូនចៅលំបាកវេទនាប្រជាជន ខ្ញុំនឹកក្នុងចិត្តក៏និយាយប្រាប់អ្នកជិតខាង ខ្ញុំថាចឹង បើសិនជាយើងចង់ត្រូវរួវគ្នាហើយចាំបាច់ធ្វើបាបប្រជាជនធ្វើអី ត្រូវរួវគ្នាជាមួយរដ្ឋាភិបាលទៅហើយ ដល់សម្លាប់គ្នាចឹង ខាងតាម៉ុក ខាង ប៉ុល ពត ឈ្លោះគ្នាទៀតពិបាកប្រជាជនហ្នឹងទៀត ។

ដានីៈ ប៉ុន្តែអ៊ំមកនៅឆ្នាំ១៩៩៦មកនៅនេះនៅជាប់អត់មានរត់ទៅណាទៀតទេ?

ផលៈ ខ្ញុំ៩៦ហ្នឹង មួយសារ ប៉ុល ពត និងតាម៉ុក វាយគ្នាហ្នឹង តានេះ ជិតផាប់ទៀត ។

ដានីៈ យ៉ាងម៉េចចឹង?

ផលៈ ចុះគេថាខ្សែនេះ ខ្សែ ប៉ុល ពត ។

ដានីៈ ចឹង?

ផលៈ ដល់ចឹងទៅតានេះគាត់ទៅតាម ពួយន ហ្នឹងមេនៅនេះណា គាត់ការពារមិនការពារទេគ្រាន់ថា កុំឲ្យឈ្លោះសគ្នាអ្នកដឹកនាំនិងអ្នកដឹកនាំហ្នឹង ដល់ហើយគេថា តាយន ក្បត់គេចាប់តាយន គេថា តាយន ធ្វើប្រជាជន គាត់និងក៏ទៅតាមដល់ទៅតាមទៅគេចាប់ តាយន ទៅតា នេះ គេវាស់ដីឲ្យដើរដែរ ។

ដានីៈ គេវាស់ដីឲ្យដើរនៅណា?

ផលៈ នៅអូរអង្រ្រែ ។

ដានីៈ នៅអូរអង្រ្រែកន្លែងយាយ ចែម ហ្នឹង?

ផលៈ ចា៎! កន្លែងយាយចែម ហ្នឹង យាយចែម ក៏គាត់ស្គាល់ដែរ យាយចែម, បងរ៉ាន់ ។

ដានីៈ ភូមិយាយចែម, យាយរ៉ាន់?

ផលៈ ចាំ! ហ្នឹងហើយនៅហ្នឹង។

ដានីៈ ឆ្នាំ៩៧ ចេញពីហ្នឹងទៅនោះទៀត។

ផលៈ ទៅនោះបានមួយឆ្នាំ។ ដល់ពេលខាងរដ្ឋាភិបាលវ៉ៃខ្លាំងមកហ្នឹងធ្លាក់ជំរំ ទៅជំរំបានមកនេះវិញ រសាត់ត្រែងលំបាកខ្លាំងណាស់។

ដានីៈ កាលអ៊ំនៅជាមួយអ៊ំយុត នៅខាងគីឡូ១២ កាលហ្នឹងដឹងថាអ៊ំយុត នៅជាមួយអ៊ំប្រុសទេ?

ផលៈ អត់ដឹងផង ទាល់តែមកនេះបានគាត់និយាយរឿងយាយយុត បានដឹងខ្ញុំស្គាល់តែតាំយាយយុត ខ្ញុំឃើញ។

ដានីៈ គាត់និយាយប្រាប់ថាម៉េច?

ផលៈ គាត់ហៅមិត្តយុត ទៅលិចមិនដឹងនៅណា ខ្ញុំថាឈ្មោះយុត មួយនៅគីឡូ១២ ខ្ញុំថាចឹង ដឹងប៉ុណ្ណឹង អត់មាននិយាយអីទៀត។

ដានីៈ គាត់និយាយថាមិត្តយុត ធ្លាប់នៅជាមួយគាត់?

ផលៈ ចាំ!

ដានីៈ គាត់ហើយអ៊ំយុត ពីណាធ្វើធំជាង?

ផលៈ មិនដឹងទេ ខ្ញុំអត់ដឹងទេ។

ដានីៈ អ៊ំសេម?

ផលៈ អត់ដឹងរលីង ព្រោះខ្ញុំអត់នៅជាមួយគាត់។

ដានីៈ តែអ៊ំស្គាល់គាត់ដែរ?

ផលៈ លឺតែតានេះគាត់ថា កាលគាត់នៅជា ហៅបងសេមៗ។

ដានីៈ គាត់ហៅថាម៉េច?

ផលៈ ហៅបងសេមៗ នឹកបងសេម តែនិយាយរឿងអីៗអត់ដែលទេ។

ដានីៈ បងសេម ហ្នឹងធ្លាប់នៅជាមួយគាត់ដែរ?

ផលៈ ចាំ! គាត់ស្គាល់។ គាត់និយាយហ្នឹងបងសេម, បងអាន, យាយបឿន មួយទៀត សុទ្ធតែធ្លាប់ស្គាល់គ្នាដែរ តែគាត់ធ្វើអីៗខ្ញុំអត់ដឹងទេ គាត់ធ្លាប់ស្គាល់គ្នា។

ដានីៈ គាត់អត់មានដែលនិយាយរឿងព្រះអង្គម្ចាស់ ដារ៉ាដេប៉ូ ប្រាប់អ៊ំទេ?

ផលៈ អត់។

ដានី៖ ដល់ពេលនៅអូរអង្ក្រែដែលថាមានរឿងរ៉ាវ តាម៉ុក ហើយនិងប៉ុល ពត ឈ្មោះគ្នាហ្នឹង គេឲ្យអ៊ំប្រុសទៅនៅ?

ផលៈ ហ្នឹងអូរអង្ក្រែហ្នឹងដែរ ។

ដានី៖ បានរយៈពេលប៉ុន្មានបានមកនេះ?

ផលៈ ទាល់តែអ៊ំជុំ, អ៊ំកែវ នេះគាត់ចូលទៅរដ្ឋាភិបាលទៅ ។ រដ្ឋាភិបាលលើក រុញមកទៅ បានទៅដំរី ហើយបានគាត់សុំគេមកមុន ។ ដឹងតែកំលាំងខាងនេះខាងអ៊ំជុំ, អ៊ំកែវ ខាងតានេះដឹងគ្នាអស់ហើយ ដល់អីចឹងសុំមកបានចុះមកមុនគេ ។ កាលទៅនៅដំរីដូចមួយឆ្នាំជាងដែរ មុនយើងសមាហរណកម្ម ។

ដានី៖ ពេលដែលសមាហរណកម្មហើយអ៊ំប្រុសគាត់ធ្វើអីទៅ?

ផលៈ គាត់នៅកន្លែងគ្រូ ខាងអប់រំ ។

ដានី៖ គាត់ធ្វើប្រធាន?

ផលៈ គាត់អត់ធ្វើប្រធានទេ មានគេប្រធាន ។

ដានី៖ ពីណាគេប្រធាន?

ផលៈ ប្រធាន ពូភ័ណ្ឌ តែឥឡូវចូលនិវត្តន៍អស់ហើយ ។

ដានី៖ ពូភ័ណ្ឌ ហើយគាត់អនុ?

ផលៈ គាត់អត់អនុទេ ពូភ័ណ្ឌ, ពូស៊ិន តែឥឡូវពូស៊ិន ម៉ូតូបុកលែងនេះទៀត, ពូអុល ដូច៤-៥រូប ។

ដានី៖ នៅកន្លែងការិយាល័យអប់រំស្រុកត្រពាំងប្រាសាទហ្នឹង?

ផលៈ ចា៎!

ដានី៖ អ៊ំគាត់ឈប់តាំងពីអង្កាល់?

ផលៈ គាត់ឈប់នឹងឈឺហ្នឹង ។

ដានី៖ ឈឺ?

ផលៈ ២០០៤ ។

ដានី៖ ពីហ្នឹងទៅសាលាស្រុកត្រពាំងប្រាសាទឆ្ងាយសឹងអី?

ផលៈ ឆ្ងាយ ។

ដានី៖ គាត់ទៅធ្វើការដែរ?

ផលៈ ទៅធ្វើការ ទៅដេកហ្នឹង មកនេះតែសៅរ៍ អាទិត្យទេ មិនដែលនៅនេះទេ ការងារនៅនោះ គាត់មិនដែលនៅទេ ។

ដានីៈ យ៉ាងម៉េចកាលឆ្នាំ២០០៨ហ្នឹង គាត់ឈឺយ៉ាងម៉េច?

ផលៈ គាត់ចេះតែហេវ ហេវហូបបាយមិនកើត ខ្ញុំថាដែលគាត់តែអស់ជាតិបាយដឹងតែធ្វើទុក ហើយ មិនដឹងម៉េចទេហូបមិនកើតថ្ងៃហ្នឹងមក មកដល់ហ្នឹងប្រហែលស្មានហ្នឹងខ្ញុំដឹកគោចូល ក្រោល គាត់ស្លៀកក្រមាមួយថាអញអស់កំលាំងណាស់ ខ្ញុំថាអស់កំលាំងច្រើនដើរធ្វើអី ថាជួយដេញគោ យប់ហ្នឹងឯងឡើងឈាម អត់ដឹង ។

ដានីៈ សំរានហ្នឹង?

ផលៈ សំរានហ្នឹងអត់ដួលទេ ជិះម៉ូតូពីត្រពាំងប្រាសាទមកនេះ ថាមកនេះហ្នឹងស្អែកឡើងដាក់ សារ៉ូមហើយទៅរៀននៅសំរោង មានបានទៅណា ។

ដានីៈ ដល់ពេលម៉េចទៅ ដល់ពេលយប់ហ្នឹងឡើងឈាម?

ផលៈ ឡើងឈាមលែងនិយាយកើតៗក៏មិនចាប់អារម្មណ៍ថាឈឺ ស្មានតែគាត់ខឹង អន់ចិត្តអី ចេះ តែស្ងួរ អត់និយាយ ស្រាប់តែមើលជើង ដៃ ទន់អស់ អត់មានថ្នាំមួយគ្រាប់ ហើយមិន មានផ្លូវដូចឥឡូវទេ ខ្ញុំទៅម៉ោង៩ដល់ត្រពាំងប្រាសាទម៉ោង៥ល្ងាច អត់មានថ្នាំអីមួយ គ្រាប់ ។

ដានីៈ យកគាត់ទៅពេទ្យ?

ផលៈ យកទៅពេទ្យ ទៅដល់ហួស ទៅដល់ដាក់សារ៉ូមមួយយប់ហ្នឹង ដាក់ថ្នាំចុះឈាមហើយស្អែក ឡើងទៅសៀមរាប ដល់ទៅសៀមរាបបញ្ជូនទៅភ្នំពេញទៀតខ្លាចមិនធានាតាមផ្លូវ ខ្វាំង មែនទែនហើយមនុស្សលែងដឹងអីទាំងអស់ ។

ដានីៈ យ៉ាងម៉េច បញ្ជូនមកផ្ទះវិញ?

ផលៈ ដល់អីចឹងនៅសៀមរាបគេឲ្យខ្ញុំទៅដេកពេទ្យខេត្ត ខ្ញុំមើលទៅថាជំងឺនេះវាមិនអាចជាទេ សុំគេឲ្យវិក័យបត្រប្រើថ្នាំហ្នឹងទិញមក យកមកមើលនៅត្រពាំងប្រាសាទវិញ ប៉ុណ្ណឹងឯង ។

ដានីៈ តាំងពីហ្នឹងមកគាត់និយាយអត់បានទេ?

ផលៈ និយាយអត់បានទេ លុកៗ ។

ដានីៈ ឥឡូវហ្នឹងគាត់និយាយបានខ្លះៗដែរ?

ផលៈ អត់ទេ ទៅពេទ្យគ្លីនិកវៀតណាមនៅសៀមរាប គាត់ថាមុនដំបូងព្យាបាលជា ដល់ពេលថ្ងៃ ហ្នឹងប្រកាច់ទៅបញ្ចូលអុកស៊ីសែន គាត់ថាចាំមើលស្អែកដឹងហើយ ដល់ស្អែកមកសួរថាអឺ

នេះស្អី នេះប៉ុន្មាន គាត់ថាគាត់ឃើញៗ អត់ឆ្លើយថាប៉ុន្មានទេ ប្រាំអីថាអត់កើតទេ យកក្រណាត់ពណ៌ មកបង្ហាញទៀតអានេះពណ៌អី គាត់ឆ្លើយថាឃើញមួយម៉ាត់ អត់ដល់អីចឹងគេសន្និដ្ឋានថា មិនអាចៗ

ដានី: មិនអាចមើលជា?

ផល: ចា៎! គ្រាន់តែប៉ុណ្ណឹង បានតែប៉ុណ្ណឹងៗ

ដានី: តែឥឡូវគាត់អាចដើរបានខ្លះៗអត់?

ផល: អត់ទេៗ

ដានី: បានតែងើប?

ផល: ងើបបានតែប៉ុណ្ណឹងៗ

ដានី: ប៉ុន្តែអ៊ីនិយាយជាមួយគាត់ គាត់ស្តាប់បាន គាត់យល់?

ផល: ចា៎! ស្តាប់បាន យើងនិយាយអីប៉ុន្មានគាត់ស្តាប់បានទាំងអស់ តែឆ្លើយមកវិញអត់រួចៗ

ដានី: តែលឺគាត់ដេញទា?

ផល: បានអាហ្នឹងស្រួលៗ សឹក ហើយដេរៗ

ដានី: គាត់ចេះដេរដែរ?

ផល: ចេះដេរៗ

ដានី: ដេរម៉េចទៅ?

ផល: ដេរពេលទឹងៗ

ដានី: ហ្នឹងគាត់និយាយចេញ?

ផល: ចេញប៉ុណ្ណឹង បារី ស្អីៗ ងីងីតែប៉ុណ្ណឹងឯង អត់និយាយអីកើតៗ

ដានី: គាត់ជក់បារីដែរ?

ផល: ជក់ អត់ឈប់ទេៗ

ដានី: បងប្អូនបង្កើតគាត់នៅប៉ុន្មាននាក់ដែរនៅនេះ?

ផល: នៅនេះ៣ៗ

ដានី: ឈ្មោះអីខ្លះទៅ?

ផល: ឈ្មោះលឿន, ឈ្មោះ ពៅ នៅត្រពាំងប្រាសាទមួយ ឈ្មោះ រុន ពិការដាច់ជើងទាំងពីរៗ

ដានី: ហ្នឹងនៅត្រពាំងប្រាសាទ?

ផល: ចា៎!

ដានី៖ នៅភូមិនេះនៅតែ៣នាក់គាត់ទេ?

ផល៖ ចា៎!

ដានី៖ នៅឈ្មោះលឿន និងឈ្មោះពៅ?

ផល៖ ចា៎!

ដានី៖ នៅស្រុកកំណើតនៅមានបងប្អូននៅទេ?

ផល៖ មាន ។

ដានី៖ ឈ្មោះអីគេទៅនៅនោះ?

ផល៖ នៅនោះឈ្មោះ ឡេន, ឈ្មោះ ទូច ។

ដានី៖ នៅអណ្ដូងថ្ម?

ផល៖ នៅអណ្ដូងថ្ម ។

ដានី៖ គាត់លែងទៅស្រុកកើតតាំងពីឆ្នាំណាទៅ?

ផល៖ តាំងពីឈឺហ្នឹងមក ។

ដានី៖ គាត់ធ្លាប់ទៅស្រុកប៉ុន្មានដងដែរ?

ផល៖ ទៅច្រើនដងដែរហ្នឹង ផ្ដាច់ខ្លួនហើយមក គាត់ទៅ៣-៤ដង ។ កាលមិនទាន់ឈឺមួយឆ្នាំ៣ដង ។

ដានី៖ កំពង់ចាមគាត់ធ្លាប់ទៅទេ?

ផល៖ អត់ទេ ។

ដានី៖ ខ្ញុំរំខានអ៊ំប៉ុណ្ណឹងហើយខ្ញុំអរគុណអ៊ំច្រើនដែលផ្ដល់ ខ្ញុំសួរនាំទាក់ទងពីរឿងរ៉ាវពីជីវិតអ៊ំ ពីជីវិតអ៊ំប្រុស ខ្ញុំអរគុណអ៊ំច្រើន ។

ចប់